តម្កល់ភ្នំទឹក រៀបចំប្រទីបប្រេង រួចចូលទៅគាល់ព្រះមានព្រះភាគ

อุปสงฺกมิตฺวา ภควนฺตํ อภิวาเทตฺวา เอกมนฺตํ อฏฺฐสุ ฯ เอกมนฺตํ ฐิตา โข ชาณุสฺโสณี อุตฺตราสงฺคา ภควนฺตํ เอตทโวจุ สพฺพสนฺถริตํ สนฺตถตา เต อาสนานิ ปญฺญตฺตานิ อุทกมณิโก จ ปติฏฺฐาปิโต เตลปฺปทีโป อาโลกิโต ยสฺสทานิ เต ภควา กาลํ มญฺญตีติ ฯ อถ โข ภควา ปุพฺพณฺหสมยนฺ(๑) นิวาเสตฺวา ปตฺตจีวรมาทาย สทฺธึ ภิกฺขุสงฺฆสฺส เยน อาสนปญฺญาปนาทิวณฺณนา เตนุปสงฺกมิ อุปสงฺกมิตฺวา ปาเท ปกฺขาเลตฺวา อาสนปญฺญาปนาทิวณฺณนา ปวิสิตฺวา มชฺฌิมํ ถมฺภํ นิสฺสาย ปุรตฺถาภิมุโข นิสีทิ ฯ ภิกฺขุสงฺโฆปิ โข ปาเท ปกฺขาเลตฺวา อาสนปญฺญาปนาทิวณฺณนา ปวิสิตฺวา ปจฺฉิมภิตฺตึ นิสฺสาย ปุรตฺถาภิมุโข นิสีทิ ภควนฺตญฺเยว ปุรกฺขตฺวา ฯ ชาณุสฺโสณิปิ โข อุตฺตราสงฺคา ปาเท ปกฺขาเลตฺวา อาสนปญฺญาปนาทิวณฺณนา ปวิสิตฺวา ปุรตฺถิมภิตฺตึ นิสฺสาย ปจฺฉิมาภิมุขา นิสีทิ สพฺพาปิ ภควนฺตญฺเยว ปุรกฺขตฺวา ฯ

---

๑ ฉ. ปุพฺพณฺหสมยนฺติ ปาโฐ ส ทีฆนิกายฏฺฐกถาปิ ฯ ม. สายณฺหสมยนฺ ฯ

លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ឋិត
នៅក្នុងទីសមគួរ ។ ពួកឧបាសកទៅក្នុងជាដលិគ្រាម លុះឋិតនៅក្នុងទី
ដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រ
ព្រះអង្គដ៏ចំរើន ផ្ទះសំណាក់ យើងខ្ញុំព្រះអង្គ បានក្រាលកម្រាលសព្វ
កន្លែងហើយ អាសនៈទាំងឡាយ យើងខ្ញុំព្រះអង្គបានតាក់តែងហើយ ភ្លុង
ទឹក យើងខ្ញុំព្រះអង្គបានតម្កល់ទុកហើយ ប្រទីបប្រេង យើងខ្ញុំព្រះអង្គ
បានរៀបចំហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគសំគាល់
នូវកាលគួរក្នុងកាលឥឡូវនេះ ។ លំដាប់នោះឯង ព្រះមានព្រះភាគ
ទ្រង់ស្បង់ទ្រង់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ស្តេចចូលទៅ
កាន់ផ្ទះសំណាក់ព្រមដោយភិក្ខុសង្ឃ លុះស្តេចទៅដល់ហើយ ទ្រង់ដំរះ
ព្រះបាទ ហើយស្តេចចូលទៅកាន់ផ្ទះសំណាក់ ទ្រង់គង់បែរព្រះកន្ត្រៃទៅ
ទិសខាងកើត ផ្នែកនឹងសសរកណ្តាល ។ ឯភិក្ខុសង្ឃ ក៏ហោងបាទាល់
រូប ចូលទៅកាន់ផ្ទះសំណាក់ ហើយអង្គុយបែរមុខទៅទិសខាងកើតអែប
នឹងជញ្ជាំងខាងលិច គាល់ព្រះមានព្រះភាគ ។ ពួកឧបាសកនៅក្នុងជាដ-
លិគ្រាម បានលាងដើងរួចហើយ ចូលទៅកាន់ផ្ទះសំណាក់អង្គុយបែរមុខ
ទៅទិសខាងលិច អែបនឹងជញ្ជាំងខាងកើត គាល់ព្រះមានព្រះភាគដែរ ។

(៧៩) អថខោ ភគវា ចាឧលិង្គាមិយេ ឧចាសកេ អាមន្តេសិ បញ្ចមេ គហបតយោ អានន្ទកា ទុស្សីលស្ស សីលវិបត្តិយា ។ កតមេ បញ្ច ។ ឥធ គហបតយោ ទុស្សីលោ សីលវិបន្នោ បមាទាធិការណំ មហាតិ កោគ-ជានឹ ឯតទត្ថតិ អយំ បឋមោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីល-ស្ស សីលវិបន្នស្ស ចាបរោ តិត្ថិសង្ឃោ អាវុត្តិ-តិ អយំ ទុតិយោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិ-យា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិ-បន្នោ យញ្ញទេវ(១) បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សម-ណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ អយំ តតិ-យោ អាទីនវោ ទុស្សីលស្ស សីលវិបត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ អយំ ចតុត្ថោ អាទីនវោ ទុស្សីលស្ស សីលវិប-ត្តិយា ។ បុន ចបរំ គហបតយោ ទុស្សីលោ សីលវិបន្នោ

---

១ ម. ឧ. មយំ យេវ ។

(៧៩) លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់នឹងពួកឧបាសក អ្នកឋុាដលិគ្រាមថា ម្នាលគហបតីទាំងឡាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិនេះមាន ៥ ប្រការ ។ ទោសទាំង ៥ ប្រការនោះតើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល កង៍លោកនេះ តែងដល់នៅសេចក្តីវិនាសនៃភោគៈដ៏ធំ មានសេចក្តីប្រមាទជាហេតុ នេះជាទោសទី ១ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត កិត្តិសព្ទដ៏អាក្រក់នៃបុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងផ្សាយទៅសព្វទិស នេះជាទោសទី ២ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ចោះចូលទៅរកបរិសទ្យណា ។ គឺខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ជាអ្នកមិនក្លៀវក្លា ចូលទៅទាំងអៀនអន់ នេះជាទោសទី ៣ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ជាបុគ្គលវង្វែងវង្វើមរណកាល នេះជាទោសទី ៤ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល

កាយសុច្ចេ កេនចិ បរម្មុខេ អត្ថាយំ ទុក្កដំ វិនិច្ឆិនិតំ
ឯវមាទិ ឧបបជ្ជតិ អយំ បញ្ចមោ អាទីនវោ ទុស្សីលស្ស
សីលវិបត្តិយា ។ ឥមេ ខោ គហបតយោ បញ្ច អា-
ទីនវា ទុស្សីលស្ស សីលវិបត្តិយា ។

(៨០) បញ្ចិមេ គហបតយោ អានិសំសា សីលវ-
តោ សីលសម្បទាយ ។ កតមេ បញ្ច ។ ឥធ គហ-
បតយោ សីលវា សីលសម្បន្នោ អប្បមាទាធិការណំ
មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ អយំ បឋមោ អានិសំ-
សោ សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហ-
បតយោ សីលវតោ សីលសម្បន្នស្ស កល្យាណោ
កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អយំ ទុតិយោ អានិសំសោ
សីលវតោ សីលសម្បទាយ ។ បុន ចបរំ គហបត-
យោ សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧប-
សង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ
យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ

លុះបែកធ្លាយពង្គកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសទី ៥ នៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ ។ ម្នាលគហបតីចាំងឆ្លាយ ទោសនៃបុគ្គលទ្រុស្តសីល នៃសីលវិបត្តិ មាន ៥ ប្រការនេះឯង ។

(๘๐) ម្នាលគហបតីចាំងឆ្លាយ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទានេះ មាន ៥ ប្រការ ។ អានិសង្ស ៥ ប្រការនោះតើដូចម្តេចខ្លះ ។ ម្នាលគហបតីចាំងឆ្លាយ បុគ្គលមានសីល ដល់ព្រមដោយសីល ក្នុងលោកនេះ រមែងបានគំនរទ្រព្យដ៏ធំ ដែលមានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីចាំងឆ្លាយ មួយទៀត កិត្តិសព្ទដ៏ពីពេរបស់បុគ្គលមានសីល ដល់ព្រមដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីចាំងឆ្លាយ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ទោះចូលទៅរកបរិសទ្យណា ។ គឺខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ជាបុគ្គលមានសេចក្តីក្លៀក្លា

อุปสงฺกมติ อุปสงฺกมิตฺวา เอวมาห อยญฺจ หิ ภนฺเต อาฬารสฺส กาลามสฺส สีลวาปิ สีลสมฺปนฺโน ปญฺญวาปิ ปญฺญาสมฺปนฺโน อมฺหากญฺจ เอตทโหสิ อยญฺจ หิ ภนฺเต อาฬารสฺส กาลามสฺส สีลวาปิ สีลสมฺปนฺโน ปญฺญวาปิ ปญฺญาสมฺปนฺโน กายสฺส เภทา ปรมฺมรณา สุคตึ สคฺคํ โลกํ อุปปชฺเชยฺย อยญฺจ ปน โข อาฬารสฺส กาลามสฺส สีลวาปิ สีลสมฺปนฺโน ปญฺญวาปิ ปญฺญาสมฺปนฺโน ตสฺส โข ปน อาฬารสฺส กาลามสฺส ปญฺญวาปิ สีลสมฺปนฺโน

ចូលទៅដោយការមិនអៀនអន់ នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីចាំដែរឬទេ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល ជាបុគ្គលមិនវង្វែងវង្វើមរណកាល នេះជាអានិសង្សទី ៤ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីចាំដែរឬទេ មួយទៀត បុគ្គលមានសីល ដល់ព្រមដោយសីល លុះបែកធ្លាយពីកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុងលោកគឺមនុស្សសុគតិនឹងឋានសួគ៌ នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល នៃសីលសម្បទា ។ ម្នាលគហបតីចាំដែរឬទេ អានិសង្សនៃបុគ្គលមានសីល នៃសីលសម្បទា មាន ៥ ប្រការនេះឯង ។

(៨១) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ញុំាងពួកឧបាសក អ្នកឋាដលិគ្រាម ឲ្យឃើញច្បាស់ ឲ្យសមាទាន ឲ្យក្លៀវក្លា ឲ្យរីករាយដោយធម្មីកថា អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលគហបតីចាំដែរឬទេ រាត្រីអស់ហើយ ចូរអ្នកចាំដែរឬសំគាស់នូវកាលដ៏សមគួរ ក្នុងកាលឥឡូវនេះចុះ ។ ពួកឧបាសកអ្នកឋាដលិគ្រាម ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ

อุฏฺฐายาสนา ภควนฺตํ อภิวาเทตฺวา ปทกฺขิณํ กตฺวา ปกฺกมึสุ ฯ อถโข ภควา อจิรปฺปกฺกนฺเตสุ ฉาฬิ-กฺกามิยេสุ อุกาสเกสุ สุญฺญาคารํ อาวิสิ ฯ

[๘๒] เตน โข[๑] ปน สมยेน สุนีธวสฺส-การา มคธมหามตฺตา ฉาฬิกฺกาเม นครํ มาเปนฺติ วชฺชีนं ปฏิพาหาย ฯ เตน โข ปน สมยेน สมฺพหุลา เทวตาโยเ สหสฺเสว[๒] ฉาฬิกฺกาเม วตฺถูนิ ปริคฺคณฺหนฺติ ฯ ยสฺมึ ปเทเส มหาสกฺกา เทวตา วตฺถูนิ ปริคฺคณฺหนฺติ มหาสกฺกานं ตตฺถ ฆรานิ ภาปมหามตฺตานं จิตฺตานิ นมนฺติ นิเวสนานิ มาเปตุं ยมฺหิ[๓] ปเทเส มชฺฌิมา เทวตา วตฺถูนิ ปริคฺคณฺหนฺติ มชฺฌิมานं ตตฺถ ฆรานิ ภาปมหามตฺตานं จิตฺตานิ นมนฺติ นิเวสนานิ มาเปตุं ยมฺหิ ปเทเส นีจา เทวตา วตฺถูนิ ปริคฺคณฺหนฺติ นีจานं ตตฺถ ฆรานิ ภาปมหามตฺตานं จิตฺตานิ นมนฺติ นิเวสนานิ มาเปตุं ฯ อทฺทสา

---

๑ ม. เทเสฺว สตฺต ฯ ๒ ฉ. สหสฺสเสฺสว ฯ ๓ ฉ. ม. ยสฺมึ ฯ

ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ
ហើយចេញទៅ ។ កាលដែលពួកទុជ្ជាសកអ្នកជាបដលិគ្រាម ចេញទៅ
មិនយូរប៉ុន្មាន ព្រះមានព្រះភាគ ក៏ទ្រង់ស្តេចចូលទៅកាន់ផ្ទះសូត្រ ។

(៨២) សម័យនោះឯង សុនីធៈនឹងវស្សការព្រាហ្មណ៍ជាមហាមាត្រ
កំពង់នៃមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេច
ក្នុងដែនវជ្ជី ។ សម័យនោះឯង ទេវតាប្រើនពួក ចំនួនមួយពាន់ ។
គន់មើលទីដីសង់ផ្ទះ ក្នុងបាដលិគ្រាម ។ ពួកទេវតាដែលមានស័ក្តិធំ
គន់មើលទីដីសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់ស្តេចនគរមហាមាត្រ
ទាំងឡាយដែលមានស័ក្តិធំ ក៏នុនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេស
នោះ ពួកទេវតាដែលមានស័ក្តិយ៉ាងកណ្តាល គន់មើលទីដីសង់ផ្ទះ
ក្នុងប្រទេសណា ចិត្តរបស់ស្តេចនគរមហាមាត្រទាំងឡាយ ដែល
មានស័ក្តិយ៉ាងកណ្តាល ក៏នុនទៅដើម្បីសាងនិវេសនដ្ឋាន ក្នុងប្រទេស
នោះ ពួកទេវតាដែលមានស័ក្តិទាប គន់មើលទីដីសង់ផ្ទះក្នុងប្រទេស
ណា ចិត្តរបស់ស្តេចនគរមហាមាត្រទាំងឡាយ ដែលមានស័ក្តិទាប
ក៏នុនទៅដើម្បីសាងនិវេសនដ្ឋានក្នុងប្រទេសនោះ ។ ព្រះមានព្រះភាគ

ខោ ភគវា ឥព្ភេន គហបតិនា វិសុទ្ធេន អតិក្កន្តមានុ-
សកេន តា ទេវតាយោ សមាសេ្សវ ចាដលិំ គាមេ
វត្តេតិ បរិក្ខណ្ហាតិយោ ។ អដ្ឋខោ ភគវា រត្តិយា
បច្ចូសសមយេ បច្ចុដ្ឋាយ អាយស្មន្តំ អានន្ទំ អាម-
ន្តេសិ តេ្រា ន្ុ ខោ អានន្ទ ចាដលិំ គាមេ ឧតរំ
មាបេតីតិ ។ សុនីធវស្សការោ ភន្តេ មគធមហាមត្តោ
ចាដលិំ គាមេ ឧតរំ មាបេតិ វជ្ជីនំ បដិពាហាយាតិ ។
សេយ្យថាបិ អានន្ទ ទេវេហិ តាវត្តឹសេហិ សទ្ធឹ ស-
ល្លាបោ មន្តេតា ឱវរេយ្យ ខោ អានន្ទ សុនីធវស្សការោ
មគធមហាមត្តោ ចាដលិំ គាមេ ឧតរំ មាបេតិ វជ្ជីនំ បដិ-
ពាហាយ ឥធាហំ អានន្ទ អទ្ទសំ ឥព្ភេន គហបតិនា វិសុទ្ធេ-
ន អតិក្កន្តមានុសកេន សព្ពហុលា ទេវតាយោ សមា-
សេ្សវ ចាដលិំ គាមេ វត្ថូនិ បរិក្ខណ្ហាតិយោ យស្មិំ បទេសេ
មហេសក្ខា ទេវតា វត្ថូនិ បរិក្ខណ្ហាតិ មហេសក្ខានំ តត្ថ
រញ្ញំ ភដមហាមត្តានំ បិត្តានិ ឧមង្គេ និវេសនានិ មា-
បេន្តុំ យស្មិំ បទេសេ មជ្ឈិមា ទេវតា វត្ថូនិ បរិក្ខណ្ហាតិ

ឃានទតយើញពួកទេវតាទាំងនោះ ចំនួនមួយពាន់ ។ កំពុងគន់មើលទីដ៏
សង់ផ្ទះ ក្នុងបាដលិគ្រាមដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់
មនុស្សសោមញ្ញ ។ ទើបព្រះមានព្រះភាគ ទ្រង់តើនឡើងក្នុងបច្ចូសសម័យ
នៃរាត្រី ហើយត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ អ្នក
ណាហ្ន៎ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ។ ព្រះអានន្ទមានអាយុ
ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន សុនីធៈនឹងវស្សការព្រាហ្មណ៍
ជាមហាមាត្រក្នុងដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បី
ការពារពួកស្តេចវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សក្កទេវពជ
បានប្រឹក្សាជាមួយនឹងពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្ស យ៉ាង
ណាមិញ ម្នាលអានន្ទ សុនីធៈនឹងវស្សការព្រាហ្មណ៍ជាមហាមាត្រ ក្នុង
ដែនមគធៈ នាំគ្នាសាងក្រុង ក្នុងបាដលិគ្រាម ដើម្បីការពារពួកស្តេចវជ្ជី
ក៏ដូច្នោះដែរ ម្នាលអានន្ទ ក្នុងទីនេះ តថាគតបានឃើញពួកទេវតា
ជាច្រើន ទាំងពាន់ ។ កំពុងគន់មើលទីដីសង់ផ្ទះក្នុងបាដលិគ្រាម ដោយ
ទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សសោមញ្ញ ពួកទេវតាដែល
មានស័ក្តិធំ គន់មើលទីដីសង់ផ្ទះ ក្នុងប្រទេសណា ចិត្តរបស់ស្តេចនឹង
ពជមហាមាត្រទាំងឡាយ ដែលមានស័ក្តិធំ ក៏នុនទៅដើម្បីសាងនិវេស-
ដ្ឋានក្នុងប្រទេសនោះ ពួកទេវតាដែលមានស័ក្តិយ៉ាងកណ្តាល គន់

มชฺฌิมานิ តត្ត រញ្ញំ ภជมหามត្តានំ ចិត្តានิ ឧមង្គ
និវេសនានិ មាបេតុំ យម្ហិ បទេសេ ឥទានេ វត្ថុ
បរិក្ខណ្ហាតិ ឥទានំ តត្ត រញ្ញំ ភជមហាមត្តានំ ចិត្តានិ
ឧមង្គ និវេសនានិ មាបេតុំ យាវតា អានន្ទ អរិយំ
អាយតនំ យាវតា វណិប្បថោ ឥទំ អគ្គនគរំ ភវិស្សតិ
ភាជលិបុត្តំ បុដភេទនំ ភាជលិបុត្តស្ស ខោ អានន្ទ
តយោ អន្តរាយា ភវិស្សន្តិ អគ្គិតោ វា ឧទកតោ វា
មិថុភេទា វាតិ ។

[๘๓] អថខោ សុនីធវស្សការា មគធមហាមត្តា
យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវតា
សទ្ធិំ សម្មោទិំសុ សម្មោទនីយំ កថំ សារណីយំ
វីតិសារេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ សុ-
នីធវស្សការា មគធមហាមត្តា ភគវន្តំ ឯតទវោចុំ អធិវា-

មើលទីដ៏សង៎ផ្ទះកង៏ប្រទេសណា ចិត្តរបស់ស្តេចនឹងពាជមហាមាត្រទាំង
ឡាយដែលមានស័ក្តិយ៉ាង៎តណ្តាល កំនុងទៅដើម្បីសាង៎និវេសនដ្ឋាន
ក្នុង៏ប្រទេសនោះ ពួកទេវតាដែលមានស័ក្តិតាប គន់មើលទីដ៏សង៎ផ្ទះ
ក្នុង៏ប្រទេសណា ចិត្តរបស់ស្តេចនឹងពាជមហាមាត្រទាំង៎ឡាយ ដែល
មានស័ក្តិតាប កំនុងទៅដើម្បីសាង៎និវេសនដ្ឋានក្នុង៏ប្រទេសនោះ ម្នាល
អានន្ទ ទីប្រជុំនៃមនុស្សជាអរិយៈ មាននៅកំណត់ត្រឹមណា ផ្លូវឈ្មួញ
មាននៅកំណត់ត្រឹមណា នគរនេះ នឹង៎បានជានគរថ្កុំថ្កើង៎ មានឈ្មោះ
ថា ក្រុង៏បាដលិបុត្រ ហាក់ជាកន្ទែង៏សម្រាប់ស្រោយបង្វែចទ្រព្យ កំណត់
ត្រឹមណោះ ម្នាលអានន្ទ តែក្រុង៏បាដលិបុត្រនឹង៎មានសេចក្តីអន្តរាយ ៣
យ៉ាង៎ គឺអន្តរាយដោយភ្លើង៎ ១ ដោយទឹក ១ ដោយការបែកគ្នា ១ ។

(៨៣) គ្រានោះ សុនិធៈនឹង៎វស្សការព្រាហ្មណ៍ ជាមហាមាត្រក្នុង៏
ដែនមគធៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ
ក៏ពោលពាក្យព្រាក់ទាក់ សំណេះសំណាល ជាមួយនឹង៎ព្រះមានព្រះភាគ
លុះបញ្ចប់ពាក្យដែលគួររីករាយ នឹង៎ពាក្យដែលគួរលឹកហើយ ក៏បានឋិត
នៅក្នុង៏ទីសមគួរ ។ សុនីធៈនឹង៎វស្សការព្រាហ្មណ៍ជាមហាមាត្រ កង៏ដែន
មគធៈ លុះឋិតនៅក្នុង៏ទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ

សេតុ ឆោ ភវេ(๑) ភវំ គោតមោ អដ្ឋតិយា ភគ្គំ
សង្ឃំ កិត្តេសិ ឆ្ឌេតិ ។ អនិកាសេសិ ភគវា តុណ្ហី-
ភាវេន ។ អថខោ សុនីធវស្សការោ មគធមហាមត្តោ
ភគវតោ អនិកាសនំ វិទិត្វា យេន សកោ អាវាសោ
តេនុបសង្កមិ ឧបសង្កមិត្វា សកេ អាវាសេ បណីតំ
ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ
អារោចាបេសុំ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។
អថខោ ភគវា បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមា-
ទាយ សង្ឃេ កិត្តេសង្ឃេន យេន សុនីធវស្សការស្ស
មគធមហាមត្តស្ស និវេសនំ អាវាសោ តេនុបសង្កមិ ឧបសង្កមិ-
ត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សុនីធវស្ស-
ការោ មគធមហាមត្តោ ពុទ្ធប្បមុខំ កិត្តេសង្ឃំ បណីតេន
ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសុំ សម្ប-
វារេសុំ អថខោ សុនីធវស្សការោ មគធមហាមត្តោ ភគ-
វន្តំ ភុត្តាវិំ ឱនីតបត្តបាណិំ អញ្ញតរំ នីចំ អាសនំ

---

๑ ម. ភវេសេវ្ហោ ឥត្តិ ។

ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះគោតមដ៏ចំរើន ព្រមដោយភិក្ខុសង្ឃ ទទួលភត្តរបស់យើងខ្ញុំតាំងឡាយ ដើម្បីឆាន់ក្នុងថ្ងៃនេះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ លុះសុនីធៈនឹងវស្សការព្រាហ្មណ៍ជាមហាមាត្រ ក្នុងដែនមគធៈដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ បានតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងលំនៅរបស់ខ្លួន រួចហើយ ទើបឲ្យគេក្រាបទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយចាត្រទឹងចីវរក្នុងបុព្វណ្ហសម័យហើយ ស្តេចចូលទៅកាន់លំនៅរបស់សុនីធៈ នឹងវស្សការព្រាហ្មណ៍ជាមហាមាត្រ ក្នុងដែនមគធៈ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលបម្រុង ។ ទើបសុនីធៈនឹងវស្សការព្រាហ្មណ៍ជាមហាមាត្រក្នុងដែនមគធៈ អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ត្រាតែភិក្ខុសង្ឃហាមឃាត់ ។ លំដាប់នោះ សុនីធៈនឹងវស្សការព្រាហ្មណ៍ជាមហាមាត្រក្នុងដែនមគធៈ (កំណត់ដឹងថា) ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ជាក់ព្រះហស្តចុះអំពីចាត្រហើយ ក៏កាន់យកអាសនៈតាប

តហោត្វា ឯតមត្ថំ ជិនសីហិសុ ។ ឯតមត្ថំ ជិនិត្វេ
ខោ សុជិតវាសវត្តាវេ មតឆមហាមត្តេ តតភ ឥមាហិ
តាថាហិ អនុមោទិ

(៨៤) យស្មឹ បទេសេ តាបេត្វតិ
ភាសំ បណ្ឌិតជាតិយោ(๑)
សីលវន្តេត្ថ តោវេត្វា
សញ្ញតេ ព្រហ្មចារិនោ(๒) ។
យា តត្ថ ទេវតា អាសុំ(๓)
តាសំ ទក្ខិណមាទិសេ
តា បូជិតា បូជយន្តិ(๔)
មានិតា មានយន្តិ នំ ។
តតោ នំ អនុកម្បន្តិ
មាតា បុត្តំវ ឱរសំ
ទេវតានុកម្បិតោ ភោសោ
សទា ភទ្រានិ បស្សតីតិ ។

---

๑ ឱ. បណ្ឌិតជាតិកោ ។ ๒ ឱ. ព្រហ្មចារយោ ។ ម. ព្រហ្មចរិយេ ។ ๓ ឱ. អាសុ ។
๔ ម. បូជិតា បូជយន្តិ នំ ។

มฺหิ ฯ ลุ:สุนีธ:นามโก วสฺสกาโร พฺราหฺมโณ ปาฏลิคาม-มหามาตฺตกาเล ปาฏลิคามสฺมิ มคธ: อคฺคนครตฺตาย ปติฏฺฐาปิยมาเน ฯ

ก็ครั้งนั้นแล ลุ:สุนีธ:พราหมณ์วัสสการะ ได้เป็นมหามาตย์ในกาลเป็นที่ปฏิสังขรณ์ปาฏลิคามให้เป็นนครอันประเสริฐกว่าเขาในแคว้นมคธ ฯ

ตทา ตสฺมิ ปาฏลิคามสฺมิ เทวตา วตฺถุปริคฺคหณตฺถาย สหสฺสเมกํ ปหาย ทฺวาทสโยชนิกาย ปาฏลิคามสีมาย สตสหสฺสเมกํ ปหาย ทฺวาทสโยชนิกาย ปาฏลิคามสีมาย สตสหสฺสเมกํ ปหาย ทฺวาทสโยชนิกาย ปาฏลิคามสีมาย สตสหสฺสเมกํ ปหาย ทฺวาทสโยชนิกาย ปาฏลิคามสีมาย ตีสุ ฐาเนสุ ตีสุ ฐาเนสุ ตีสุ ฐาเนสุ ตีสุ ฐาเนสุ

(៨៥) អថខោ ភគវា សុដិន្ទវស្សការេ មគធមហាមត្តេ ឥមានិ តាទិសានិ អនុត្តរានិ ទុដ្ឋាយាសានិ បញ្ញាបេសិ ។ តេន ខោ បន សមយេន សុដិន្ទវស្សការោ មគធមហាមត្តោ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុវាតំ ហោន្តំ យេនន្ធ សមណោ គោតមោ ទ្វារេន និក្ខមិស្សតិ តំ គោតមទ្វារំ នាម ភវិស្សតិ យេន តិត្ថេន តង្ខណទី[1] តរិស្សតិ តំ គោតមតិត្ថំ នាម ភវិស្សតីតិ ។ អថខោ ភគវា យេន ទ្វារេន និក្ខមិ តំ គោតមទ្វារំ នាម អហោសិ ។ អថខោ ភគវា យេន តង្ខណទី តេនុបសង្កមិ ។ តេន ខោ បន សមយេន តង្ខណទី បូរា ហោតិ សមតិត្តិកា កាកបេយ្យា ។ អថខ្វស្ស មនុស្សា នាវំ បរិយេសន្តិ អថខ្វស្ស ទុន្នាវំ បរិយេសន្តិ អថខ្វស្ស ខុទ្ទកំ នាវំ ឱលុព្ភ ឱលុព្ភ[2] តង្ខណាមា ។ អថខោ ភគវា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ តង្ខណេ ឯតិយា ឱរិមេ តីរេ អន្តរហិតោ បារិមេ តីរេ បច្ចដ្ឋាសិ សទ្ធិំ កិក្ខុសង្ឃេន ។

---

១ ខ. តង្ខំ ឆទិ ។ ២ ខ. អបរាបរំ ។

[៨៥] លុះព្រះមានព្រះភាគ ទ្រង់អនុមោទនា ដោយគាថាទាំងនេះដល់សុនីធៈនឹងវស្សការព្រាហ្មណ៍ ដែលជាមហាមាត្រក្នុងដែនមគធៈហើយ ទ្រង់ក្រោកអំពីអាសនៈចេញទៅ ។ សម័យនោះឯង សុនីធៈនឹងវស្សការព្រាហ្មណ៍ ជាមហាមាត្រក្នុងដែនមគធៈ បានដើរតាមព្រះមានព្រះភាគអំពីខាងក្រោយ ។ ដោយតាំងចិត្តថា ថ្ងៃនេះព្រះសមណគោតម ទ្រង់ស្តេចចេញតាមទ្វារណា ទ្វារនោះនឹងបានឈ្មោះថា គោតមទ្វារ ទ្រង់ស្តេចឆ្លងទន្លេគង្គាត្រង់កំពង់ណា កំពង់នោះនឹងបានឈ្មោះថា គោតមតិត្ថៈ ។ ព្រះមានព្រះភាគ ទ្រង់ស្តេចចេញតាមទ្វារណា ទ្វារនោះក៏បានឈ្មោះថា គោតមទ្វារ ចាប់ដើមតាំងអំពីនោះមក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅត្រង់ទន្លេគង្គានោះ ។ សម័យនោះឯង ទន្លេគង្គាកំពុងពេញប្រៀប ល្មមសត្វក្អែកទំលើមាត់ច្រាំងនុនផឹកទឹកបាន ។ មនុស្សទាំងឡាយ ដែលប្រាថ្នានឹងឆ្លងអំពីត្រើយម្ខាង ទៅកាន់ត្រើយម្ខាង ពួកខ្លះក៏ស្វែងរកទូក ពួកខ្លះក៏ស្វែងរកផែ ពួកខ្លះក៏ចងក្ផូន ។ លំដាប់នោះ ព្រះមានព្រះភាគ ស្រាប់តែឃាត់ព្រះអង្គអំពាត្រើយទន្លេគង្គាខាងអាយ ទៅប្រាកដព្រះអង្គក្នុងត្រើយខាងនាយ ព្រមទាំងភិក្ខុសង្ឃ ដូចជាបុរសដែលមានកម្លាំង លាកំភួនដៃដែលបត់ហើយ ឬបត់កំភួនដៃដែលលាហើយ ។

អថ្ខសា ខោ ភគវា តេ មល្លេ អាមន្តេសិ អភិវាទេថ្ខ ភន្តេ
បរិយេសន្តេ អភិវាទេថ្ខ ចុន្ទំ បរិយេសន្តេ អភិវាទេថ្ខ កុលំ
ពន្ធន្តេ ថាវ ថាវំ គន្តុកាមេ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ
ឧទានំ ឧទានេសិ

យេ តត្ថ អឝ្ឈាវំ សរំ
សេតុំ កត្វាន វិសជ្ជ បល្លលានិ
កុលំ ឥនោ ច ពន្ធតិ(๑)
តំ ណ្ណា មេឃាវិនោ ឥឝាតិ ។

ពុទ្ធភាណវារំ បឋមំ ។

(๘๖) អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន កោដិគ្គាមោ តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធិំ យេន កោដិគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា កោដិគ្គាមេ វិហរតិ ។ តត្រ ខោ ភគវា

๑ ឆ.ម. កុលំ ហិ ឥនោ បពន្ធតិ ។

ព្រះមានព្រះភាគ ទ្រង់ទតឃើញមនុស្សពាំងនោះ ពួកខ្លះកំពុងស្វែងរកខ្លួក ពួកខ្លះកំពុងស្វែងរកផែ ពួកខ្លះកំពុងចងក្បួន បំណាច់ទឹងធ្លុងអំពីត្រើយម្ខាង ទៅត្រើយម្ខាង ។ ព្រះអានន្ទព្រះភាគ ទ្រង់ជ្រាបច្បាស់នូវហេតុនុ៎ះហើយ ក៏ទ្រង់បន្ទឺឧទាននេះ ក្នុងវេលានោះថា

ជនពាំងឆ្ការណា ឆ្លងទន្លេទឹងស្ទឹង គឺតណ្ហា ដែលជ្រាលជ្រៅធំទូលាយបាន ជនពាំងឆ្ការនោះ រមែងធ្វើស្ពានគឺអរិយមគ្គ លះបង់នូវទំនាបដែលពេញដោយទឹក ឆ្លងផុតទៅបាន ចំណែកជនធម្មតា លុះតែចងក្បួន ទើបឆ្លងទៅបាន ឯពួកជនជាអ្នកប្រាជ្ញ (មិនចាំបាច់ក្បួន) ក៏ឆ្លងទៅបាន ។

ចប់ ពុទ្ធភាណវារៈទី ១ ។

(៨៦) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងទៅកាន់កោដិគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់កោដិគ្រាម ព្រមដោយភិក្ខុសង្ឃជាច្រើន ។ ចានពួកថា ព្រះមានព្រះភាគទ្រង់គង់ក្នុងកោដិគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ

កិក្ខូ អាមន្តេសិ ចតុន្នំ កិក្ខវេ អរិយសច្ចានំ អននុពោធា
អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ ម-
មញ្ចេវ តុម្ហាកញ្ច ។ កតមេសំ ចតុន្នំ ។ ទុក្ខស្ស កិក្ខ-
វេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវមិទំ ទីឃ-
មទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។ ទុក្ខ-
សមុទយស្ស កិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិ-
វេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ
តុម្ហាកញ្ច ។ ទុក្ខនិរោធស្ស កិក្ខវេ អរិយសច្ចស្ស អន.
នុពោធា អប្បដិវេធា ឯវមិទំ ទីឃមទ្ធានំ សន្ធាវិតំ សំស-
រិតំ មមញ្ចេវ តុម្ហាកញ្ច ។ ទុក្ខនិរោធគាមិនិយា បដិប-
ទាយ កិក្ខវេ អរិយសច្ចស្ស អននុពោធា អប្បដិវេធា ឯវ
មិទំ ទីឃមទ្ធានំ សន្ធាវិតំ សំសរិតំ មមញ្ចេវ តុម្ហាកញ្ច ។

ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសង្សារវដ្ត) អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចៈទាំង ៤ ។ អរិយសច្ចៈទាំង ៤ នោះ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខសមុទយអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់កាលជាយូរអង្វែងយ៉ាងនេះ ក៏ព្រោះតែមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ។

ตยิทํ ภิกฺขเว ทุกฺขํ อริยสจฺจํ อนุพุทฺธํ ปฏิวิทฺธํ ทุกฺข-
สมุทยา อริยสจฺจํ อนุพุทฺธํ ปฏิวิทฺธํ ทุกฺขนิโรธา
อริยสจฺจํ อนุพุทฺธํ ปฏิวิทฺธํ ทุกฺขนิโรธคามินี ปฏิปทา
อริยสจฺจํ อนุพุทฺธํ ปฏิวิทฺธํ ขุจฺฉิตา ภวตณฺหา ขีณา
ภวเนตฺติ ฉินฺนฆานิ ปุนพฺภเวติ ฯ สนมเกย ภควา สนิ
วฺหาย สุคโต อถาปรํ เอตทเวจ สตฺถา

(๘๗) จตฺตาริ อริยสจฺจานิ
ยถาภูตํ อนญฺญถา
สมฺมาทิฏฺฐิ(๑) นิยมฺหาสา
ตาสุ ตาเยว(๒) ชาติสุ ฯ
ตานิ เอตานิ ทิฏฺฐานิ
ภวเนตฺติ สมูหตา
ขุจฺฉิตา มูลา ทุกฺขสฺส
ฉินฺนฆานิ ปุนพฺภเวติ ฯ

---

๑ ฐ. สมฺมาทิฏฺฐิ ฯ ๒ ฐ. ตาเยว ฯ

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនោះឯង ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខសមុទយអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលបុគ្គលបានត្រាស់ដឹង បានចាក់ធ្លុះហើយ ភវតណ្ហា គឺសេចក្តីប្រាថ្នាកង់ភាក៏សូន្យទៅ ឱ្យ គឺតណ្ហាដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏អស់ទៅ ភពថ្មីក្នុងកាលឥឡូវនេះក៏មិនមានឡើយ ។ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះហើយ ព្រះសុគតលុះត្រាស់ពាក្យនេះហើយ ព្រះសាស្តាទ្រង់ត្រាស់ពាក្យដូច្នេះដទៃអំពីពាក្យនោះថា

(๘๗) ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែង ក្នុងជាតិនោះ ។ ឯង ក៏ព្រោះតែមិនបានឃើញនូវអរិយសច្ចទាំង ๔ តាមពិត ។ ឯអរិយសច្ចទាំង ๔ នោះ បើបុគ្គលបានឃើញហើយ ឱ្យ គឺតណ្ហា ដែលអាចនាំសត្វអំពីភពមួយទៅភពមួយ ក៏ដាច់ហើយ ឫសគល់របស់ទុក្ខក៏ពុករលួយហើយ ភពថ្មីទៀតក្នុងកាលឥឡូវនេះមិនមានឡើយ ។

[៨៨] តត្របិ សុទំ ភគវា តោដេ្តយ្យមេ វិហរន្តោ ឯតទេវ ពហុលំ តិក្ខត្តុំ ឆម្មឹ តថំ តថេតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

[៨៩] អថខោ ភគវា តោដេ្តយ្យមេ យថាភិរន្តំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន ជាណុស្សោណិ(១) តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ជាណុស្សោណិ តទវសរិ ។ តត្រ(២) សុទំ ភគវា ជាណុស្សោណិំ វិហរតិ តិញ្ចកាវសថេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ

---

១ ម. ឆាតិកា ។ ២ ម. តត្របិ ។

(៨៨) ចានឮថា កាលព្រះមានព្រះភាគ គង់នៅក្នុងកោដិគ្រាម នោះឯង ទ្រង់ធ្វើធម្មីកថាជាច្រើន ចំពោះភិក្ខុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

(៨៩) លុះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកោដិគ្រាម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុ មកថា ម្នាលអានន្ទ មក យើងនឹងទៅកាន់នាទិកគ្រាម ។ ព្រះអានន្ទមានអាយុទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់នាទិកគ្រាមនោះ ព្រមដោយភិក្ខុសង្ឃជាច្រើន ។ ចានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងផ្ទះសំណាក់ដែលធ្វើដោយឥដ្ឋ ក្នុងនាទិកគ្រាមនោះ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

อภิวาเทตฺวา ฯเปฯ นิสีทิ ฯ ฯเปฯ นิสินฺโน โข อายสฺมา อานนฺโท ภควนฺตํ ฯเปฯ ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกเตน สทฺธึ ตตฺถ เตน อภิสมฺภายเย ฉฏฺฐา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย สุฉาตา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย สุชาตา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย กกุโธ ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกเตน สทฺธึ ตตฺถ เตน อภิสมฺภายเย กาวฬิงฺคา[๑] ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย นิโคฺรธา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย กติสฺสโก[๒] ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกเตน สทฺธึ ตตฺถ เตน อภิสมฺภายเย นนฺทา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย สนฺทา ชานาม ภนฺเต ภิกฺขู ชานิเตน ตาลเกน สทฺธึ ตตฺถ เตน อภิสมฺภายเย ฯเปฯ

๑ ฉ. กาลิงฺคา ฯ ม. กาฬิงฺคา ฯ ๒ ฉ. กติสฺสกา ฯ

ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះ
អានន្ទមានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះ
មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះសាឡ្ហៈធ្វើមរណ-
កាលក្នុងនាទិកគ្រាម គតិរបស់សាឡ្ហភិក្ខុនោះដូចម្តេច បរលោកដូចម្តេច
បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនីឈ្មោះនន្ទា ធ្វើមរណកាលក្នុងនាទិកគ្រាម
គតិរបស់ភិក្ខុនីនោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន
ឧបាសកឈ្មោះសុទត្ត ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសក
នោះដូចម្តេច បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន ឧបាសិកាឈ្មោះ
សុជាតា ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសិកានោះដូចម្តេច
បរលោកដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះកកុធៈធ្វើមរណ-
កាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះដូចម្តេច បរលោកដូចម្តេច
បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះការឌ្ភិយៈ ។ បេ ។ បពិត្រព្រះអង្គ
ដ៏ចំរើន ឧបាសកឈ្មោះនិកដៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសក
ឈ្មោះកដិស្សហៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះ
តុដ្ឋៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះសន្តុដ្ឋៈ ។ បេ ។

ភគវា[1] តាម ភគ្គេ ពុទ្ធាសតោ ។ បេ ។ សុភគវា[2] តាម ភគ្គេ ពុទ្ធាសតោ តាទិសេ តាលិតតោ តស្ស តា តតិ តោ អភិសម្ពុជ្ឈតិ ។ សាធ្យោ អានន្ទ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥមា អានន្ទ ភិក្ខុនី បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្ពាយិនី អនាវត្តិធម្មា តស្មា លោកា សុទ្ធាតា អានន្ទ ពុទ្ធាសតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតិ សុជាតា អានន្ទ ពុទ្ធាសិតោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោ-ធិបរាយនា តតុត្តរា អានន្ទ ពុទ្ធាសតោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្ពាយី អនាវត្តិធម្មា តស្មា លោកា

---

១ ឱ. ភគ្គេ ។ ២ សុភគ្គេ ។

បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះកដៈ ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ឧបាសកឈ្មោះសុកដៈ ធ្វើមរណកាលក្នុងនាទិកគ្រាម គតិរបស់ឧបាសកនោះដូចម្តេច បរលោកដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ សាឡ្ហកិក្តុបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវបេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈព្រោះអស់ទៅនៃអាសវៈសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ក្នុងបច្ចុប្បន្ន ម្នាលអានន្ទ នន្ទាកិក្តុនីជាឧបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម (អនាគាមី) ម្នាលអានន្ទ សុទត្តឧបាសក ជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀតនឹងធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ៣ ដោយមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ម្នាលអានន្ទ សុជាតាឧបាសិកា ជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ៣ ម្នាលអានន្ទ កកុដៈឧបាសក ជាឧបបាតិកសត្វ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម

តោរន្ធិម្ភោ អានន្ទ ឧបាសកោ ។បេ។ ឩតកដោ អានន្ទ ឧបាសកោ ។ តិដិស្សហោ អានន្ទ ឧបាសកោ ។ តុដ្ឋោ អានន្ទ ឧបាសកោ ។ សន្តុដ្ឋោ អានន្ទ ឧបាសកោ ។ កដោ អានន្ទ ឧបាសកោ ។ សុកដោ អានន្ទ ឧបាសកោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា បញ្ចន្នំ[1] អានន្ទ ឩនិកេ ឧបាសកា កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា ឩនិកា[2] ឯវមាទិ អានន្ទ ឩនិកេ ឧបាសកា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ឧសាតវេគាធិ[3] អានន្ទ បញ្ចន្នំ ឩនិកេ ឧបាសកា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា

---

១ ម. បញ្ចន្នំ ។ ២ ឧ. ម. សាធិកា ។ ៣ ឧ. ម. សាតិរេកានិ ។

ម្នាលអានន្ទ ការឡើងកុដាគារ ๆ បេ ๆ ម្នាលអានន្ទ និកដកុដាគារ ๆ ម្នាលអានន្ទ កដិស្សហកុដាគារ ๆ ម្នាលអានន្ទ តុដ្ឋកុដាគារ ๆ ម្នាលអានន្ទ សន្ថដ្ឋកុដាគារ ម្នាលអានន្ទ កដកុដាគារ ๆ ម្នាលអានន្ទ សុកដកុដាគារ ជាឧបបាតិកសត្ត បរិនិព្វាន ក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ ចាកលោកនោះ ព្រោះអស់នៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសកជាង ๕๐ នាក់ ដែលធ្លើមរណកាលក្នុងនាគិក-គ្រាម សុទ្ធតែជាឧបបាតិកសត្ត បរិនិព្វាន ក្នុងសុទ្ធាវាសព្រហ្មលោកនោះ ជាបុគ្គលលែងវិលត្រឡប់ ចាកលោកនោះ ព្រោះអស់នៅនៃសំយោជន: ๕ ជាចំណែកខាងក្រោម ម្នាលអានន្ទ ពួកឧបាសក ๙๖ នាក់ ដែលធ្លើមរណកាល ក្នុងនាគិកគ្រាម សុទ្ធតែជាសកទាគាមី ត្រឡប់មកកាន់លោកនេះម្តងទៀត ធ្វើទុក្ខទីបំផុតនៃទុក្ខ ព្រោះអស់នៅនៃសំយោជន: ๓ មានពាគ: ទោស: មោហ: ស្រាលស្តើង ម្នាលអានន្ទ ពួកឧបាសក ๕๑๐ នាក់ ដែលធ្លើមរណកាល ក្នុងនាគិក-គ្រាម សុទ្ធតែជាសោតាបន្នបុគ្គល ជាបុគ្គលលែងធ្លាក់ទៅ ក្នុងអបាយ

និយតា សម្ពោធិបរាយណា អនច្ឆរិយំ ខោ បនេតំ អា-
នន្ទ យំ មនុស្សភូតោ តាលំ តវេយ្យ តស្មឹ តស្មឹ ខោ(๑)
តាលតកតេ តថាគតំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆិ-
ស្សថ វិហេសាវេសា អានន្ទ តថាគតស្ស តស្មាតិហា-
នន្ទ ឆម្មាសំ ឋាម ឆម្មបរិយាយំ ទេសេស្សាមិ យេន
សមន្នាគតោ អរិយសាវកោ អាតក្ខំមាតោ អត្តនា វ
អត្តានំ ព្យាតវេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោ-
និ(๒)ខីណបេត្តិវិសយោ ខីណាបាយទុក្កតិវិនិបាតោ សោ-
តាបន្នោហមស្មិ អវិនិបាតធម្មោ និយតោ សម្ពោធិបរា-
យណោតិ តាតមោ ច សោ អានន្ទ ឆម្មាសោ ឆម្ម-
បរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាតក្ខំ-
មាតោ អត្តនា វ អត្តានំ ព្យាតវេយ្យ ខីណនិរយោម្ហិ
ខីណតិរច្ឆានយោនិ ខីណបេត្តិវិសយោ ខីណាបាយទុក្ក-
តិវិនិបាតោ សោតាបន្នោហមស្មិ អវិនិបាតធម្មោ និ-
យតោ សម្ពោធិបរាយណោតិ ឥមានន្ទ អរិយសាវកោ

---

๑ ម. បេ ។ ម. យេវ ។ ๒ ម. ខីណតិរច្ឆានបេតនិរយោ ។

ជាបុគ្គលទៀត មានសេចក្តីត្រាស់ដឹងទៅខាងមុខ ព្រោះអស់ទៅនៃ
សំយោជនៈ៣ ម្នាលអានន្ទ សត្វដែលជាមនុស្ស ធ្វើមរណកាលដោយ
ហេតុណា ហេតុនោះមិនជាអស្ចារ្យទេ ព្រោះកាលបើមនុស្សនោះ ។ ធ្វើ
មរណកាលហើយ អ្នកទាំងឡាយមុខជានឹងមកកាន់តថាគត ហើយសួរនូវ
ដំណើរនុ៎ះ ម្នាលអានន្ទ នេះជាសេចក្តីលំបាកដល់តថាគតណាស់ ម្នាល
អានន្ទ ព្រោះហេតុនោះ អរិយសាវ័កប្រកបដោយធម្មបរិយាយណា
កាលបើប្រាថ្នានឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មា
អញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ
អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែង
ធ្លាក់ចុះហើយ ជាបុគ្គលទៀត មានសេចក្តីត្រាស់ដឹងទៅក្នុងខាងមុខដូច្នេះ
តថាគតនឹងសំដែងធម្មបរិយាយនោះឈ្មោះធម្មាទាសៈ (ធម៌ដូចកញ្ចក់ឆ្ងុំ)
ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើត្រូវ
ការនឹងព្យាករ ក៏គប្បីព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់
នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ អស់
អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះ
ហើយ ជាបុគ្គលទៀត មានសេបក្តីត្រាស់ដឹងទៅក្នុងខាងមុខដូច្នេះ ចុះធម-
បរិយាយឈ្មោះធម្មាទាសៈនោះ តើដូចម្តេច ម្នាលអានន្ទ អរិយសាវ័ក

ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ឥតិបិ
សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ
សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា
ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ឥមេ អវេច្ចប្បសាទេន
សមន្នាគតោ ហោតិ ស្វាក្ខាតោ ភគវតា ធម្មោ
សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ
បច្চត្តំ វេទិតព្ពោ វិញ្ញូហីតិ សេយ្យថ អវេច្ចប្បសាទេន
សមន្នាគតោ ហោតិ សុប្បដិបន្នោ ភគវតោ សាវ-
កសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សា-
មីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ

ក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់ដល់នូវសុន្ទរស្ថាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់កំពង្វាតដូច្នេះ អរិយសាវ័កប្រកបដោយសេចក្តីជ្រះថា មិនញាប់ញ័រក្នុងព្រះធម៌ថា ធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយប្រពៃ ជាធម៌ដែលអរិយបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរនឹងហៅថាអ្នកចូរចូលមកមើលដូច្នេះបាន ជាធម៌ដែលអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងដោយជាក់ច្បាស់ក្នុងចិត្តនៃខ្លួនដូច្នេះ អរិយសាវ័កប្រកបដោយសេចក្តីជ្រះថា មិនញាប់ញ័រ ក្នុងព្រះសង្ឃថា ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយត្រង់ ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកនៃសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយសមគួរ ព្រះសង្ឃទាំងអស់នោះ

ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ អខណ្ឌេហិ អច្ឆិទ្ទេហិ អសពលេហិ អកម្មាសេហិ ភុជិស្សេហិ វិញ្ញុប្បសត្ថេហិ អបរាមដ្ឋេហិ សមាធិសំវត្តនិកេហិ អយំ ខោ[1] អានន្ទ ឆន្នាបាសោ ឆម្មបរិយាយោ យេន សមន្នាគតោ អរិយសាវកោ អាកង្ខមានោ អត្តនាវ អត្តានំ ព្យាករេយ្យ ខីណនិរយោម្ហិ ខីណតិរច្ឆានយោនិ ខីណាបេត្តិវិសយោ ខីណាបាយទុក្កតិវិនិបាតោ សោតាបន្នោម្ហិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោតិ ។ តត្រៃទំ[2] សុទំ ភគវា ញាទិកេ វិហារេ តិញ្ញកាវសថេ ឯតទេវ ពហុលំ ភិក្ខូនំ ធម្មិកថំ កត្វោ តិស្សោ ឥតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា

---

๑ ឱ. ម. ហោ សោ ។ ๒ ឱ. តត្រ ។

បើកចប់ជាគូនៃបុរសមាន ៤ បើកចប់រៀងជាបុរសបុគ្គលមាន ៨ ពួកនៃសាវ័ក
របស់ព្រះមានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមក
បូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទក្ខិណាទាន
ជាបុគ្គលដែលសត្វលោកគប្បីធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់
សត្វលោកដូច្នេះ អរិយសាវ័កប្រកបហើយដោយសីល ជាទីគាប់ចិត្ត
របស់ព្រះអរិយៈ ជាសីលមិនជាប់ មិនជ្លុះ មិនពពាល មិនពព្រុះ
ជាសីលរបស់មនុស្សអ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិន
ជ្រោកជ្រាកដោយតណ្ហានិងទិដ្ឋិ ជាសីលញុំាងសមាធិឲ្យប្រព្រឹត្តទៅបាន
ម្នាលអានន្ទ អរិយសាវ័កប្រកបដោយធម្មបរិយាយណា កាលបើ
ត្រូវការនឹងពោល ក៏គប្បីពោលខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញ
អស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បេត្តិវិស័យហើយ អស់
អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល លែងធ្លាក់ចុះ
ហើយ ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខដូច្នេះ ធម្ម-
បរិយាយនេះឯង ហៅថា ធម្មទាសៈ ។ បានឮថា ព្រះមានព្រះភាគគង់
ក្នុងផ្ទះសំណាក់ ធ្វើដោយឥដ្ឋកងនាទិកគ្រាមនោះឯង ទ្រង់ធ្វើធម្មីកថាជា
ច្រើនដល់កិកុពាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ

สีลสมาธิคาวิโต สมาธิ มหปฺผโล โหติ มหานิสංสो สมาธิปริภาวิตา ปญฺญา มหปฺผลา โหติ มหานิสංสา ปญฺญาปริภาวิตං จิตฺตං สมฺมเทว อาสวเหิ วิมุจฺจติ เสยฺยถีทං กามาสวา ภวาสวา อวิชฺชาสวาติ ฯ

(๙๐) อถโข ภควา ชานิเตน ยถากิรฺจิ วิหาริตฺวา อายสฺมนฺตं อานนฺทं อามนฺเตสิ อายามานนฺท เยน เวสาลี เตนุปสงฺกมิสฺสามาติ ฯ ฐานนฺติ โข อายสฺมา อานนฺโท ภควาโต ปจฺจสฺโสสิ ฯ อถโข ภควา มหตา ภิกฺขุสงฺเฆน สทฺธิ เยน เวสาลี ตทวสริ ฯ ตตฺร สุทං ภควา เวสาลิยํ วิหรติ อมฺพปาลิวเน ฯ ตตฺร โข ภควา ภิกฺขู อามนฺเตสิ สาตา ภิกฺขเว ภิกฺขู วิหาเรยฺย สมฺปชาโน อยํ เต[๑] อมฺหากํ อนุสาสนีติ ฯ กถญฺหิ ภิกฺขเว ภิกฺขู สาตา โหนฺติ ฯ ๘๘ ภิกฺขเว ภิกฺขู กาเย กายานุปสฺสี

๑ ฉ. ม. เป ฯ

សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិ-
សង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផល
ច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែង
រួចស្រឡះចាកអាសវៈទាំងឡាយ ដោយប្រពៃ គឺកាមាសវៈ ភវាសវៈ
អវិជ្ជាសវៈ ។

(៩០) លុះព្រះមានព្រះភាគ ទ្រង់គង់ទៅក្នុងនាទិកគ្រាម តាម
សមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា
ម្នាលអានន្ទ មក យើងនឹងទៅកាន់ក្រុងវេសាលី ។ ព្រះអានន្ទមាន
អាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើប
ព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់ក្រុងវេសាលី ព្រមដោយភិក្ខុ-
សង្ឃជាច្រើនរូប ។ ចានពួថា ព្រះមានព្រះភាគទ្រង់គង់ក្នុងអម្ពបាលិវ័ន
ទៀបក្រុងវេសាលីនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ
ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិនឹង
សម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ ។
ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុមានសតិនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំង
ឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាកាយក្នុងកាយជាប្រក្រតី ជា

វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ
អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ
ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ កិក្ខ-
វេ កិក្ខុ សតោ ហោតិ ។ កថញ្ច កិក្ខវេ កិក្ខុ សម្ប-
ជានោ ហោតិ ។ ឥធ កិក្ខវេ កិក្ខុ អភិក្កន្តេ បដិក្ក-
ន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ
សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជា-
នការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី
ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្ប-
ជានការី ហោតិ ឧច្চារបស្សាវកម្មេ សម្បជានការី
ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ
តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឯវំ ខោ កិក្ខវេ
កិក្ខុ សម្បជានោ ហោតិ ។ សតោ កិក្ខវេ កិក្ខុ វិហ-
រេយ្យ សម្បជានោ អយំ តេ អម្ហាកំ អនុសាសនីតិ ។

អ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ដ៏ធំខ្លួន មានសតិ កំចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោក គឺកាយក្នុងបានកន្ធ ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុពិចារណាធម្មក្នុងធម្មទាំងឡាយជាប្រក្រតី ជាអ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ដ៏ធំខ្លួន មានសតិ កំចាត់បង់នូវអភិជ្ឈានឹងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសតិយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាឈានទៅមុខ និងការឈានថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាក្រឡេកមើលទៅមុខនឹងក្រឡេកមើលទៅខាង ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាអង្អាញនឹងកិរិយាលាតលាដៃដើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាទ្រទ្រង់សង្ឃាដិនឹងបាត្រចីវរ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាស៊ី ផឹក ទំពា ក្រេបជញ្ជាប់ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាបន្ទោបង់ឧច្ចារៈនឹងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់និយាយនឹងការស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសម្បជញ្ញៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវមានសតិនឹងសម្បជញ្ញៈ នេះជាពាក្យប្រៀនប្រដៅរបស់តថាគតចំពោះអ្នកទាំងឡាយ ។

(๙๑) អស្សោសិ ខោ អម្ពបាលី គណិកា ភគវា កិរ វេសាលឹ អនុប្បត្តោ វេសាលិយំ វិហរតិ មយ្ហំ អម្ពវនេតិ ។ អថ ខោ អម្ពបាលី គណិកា ភទ្ទានិ ភទ្ទានិ យានានិ យោជាបេត្វា ភទ្ទំ ភទ្ទំ យានំ អភិរុហិត្វា ភទ្ទេហិ ភទ្ទេហិ យានេហិ វេសាលិយា និយ្យាសិ យេន សកោ អាវាសោ តេន ឋាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អម្ពបាលឹ គណិកំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថ ខោ អម្ពបាលី គណិកា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ

(๙๑) ស្រីផ្កាមាសឈ្មោះអម្ពបាលី បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពវនៈរបស់អាត្មាអញ ទៀបក្រុងវេសាលី ។ ទើបស្រីផ្កាមាសឈ្មោះអម្ពបាលី ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងជិះលើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លា បរសំដៅទៅកាន់អាពាមរបស់ខ្លួន ទៅដោយយានកំណត់ត្រឹមទីដែលបរយានទៅបាន រួចបុះអំពីយានដើរទៅដោយដើងទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយ ង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះស្រីផ្កាមាសឈ្មោះអម្ពបាលី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លំដាប់នោះ ស្រីផ្កាមាសឈ្មោះអម្ពបាលី លុះព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃទទួលភត្តពុំម្ងាស់ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ នាងអម្ពបាលីជាស្រីផ្កាមាស

ภควา ตุณฺหีภาวเตน ฯ อถโข อมฺพฏฺฐาลี คณิกา ภควตา อธิวาสนํ วิทิตฺวา อุฏฺฐายาสนา ภควนฺตํ อภิวาเทตฺวา ปทกฺขิณํ กตฺวา ปกฺกามิ ฯ

(๔๒) อสฺโสสุ โข เวสาลิกา ลิจฺฉวี ภควา กิร เวสาลึ อนุปฺปตฺโต เวสาลิยญฺหิ วิหรติ อมฺพฏฺฐาลิวเนติ ฯ อถโข เต ลิจฺฉวี ภทฺทานิ ภทฺทานิ ยานานิ โยชาเปตฺวา ภทฺทา ภทฺทา ยานา อภิรุหิตฺวา ภทฺเทหิ ภทฺเทหิ ยาเนหิ เวสาลิยา นิยฺยึสุ ฯ ตตฺร เอกจฺเจ ลิจฺฉวี นีลา โหนฺติ นีลวณฺณา นีลวตฺถา นีลาลงฺการา เอกจฺเจ ลิจฺฉวี ปีตา โหนฺติ ปีตวณฺณา ปีตวตฺถา ปีตาลงฺการา เอกจฺเจ ลิจฺฉวี โลหิตกา โหนฺติ โลหิตกวณฺณา โลหิตกวตฺถา โลหิตกาลงฺการา เอกจฺเจ ลิจฺฉวี ผลิกา โหนฺติ ผลิกวณฺณา ผลิกวตฺถา ผลิกาลงฺการา ฯ อถโข อมฺพฏฺฐาลี คณิกา ภทฺทกญฺเจว ภทฺทกญฺจ ลิจฺฉวึ อาจฺเฉตฺวา อาจฺเฉตฺวา ภทฺทกญฺเจว ภทฺทกญฺจ ยุเชตฺวา ยุเชตฺวา ปฏิวาเตสิ ฯ

ដឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។

(៤២) ពួកស្តេចលិច្ឆវីអ្នកនៅក្នុងក្រុងវេសាលីបានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ក្រុងវេសាលីហើយ ទ្រង់គង់នៅក្នុងអម្ពបាលិវន ទៀបក្រុងវេសាលី ។ ទើបស្តេចលិច្ឆវីទាំងនោះ ឲ្យគេរៀបចំយានទាំងឡាយដ៏ថ្លៃថ្លា ហើយឡើងគង់លើយានដ៏ថ្លៃថ្លា ចេញអំពីក្រុងវេសាលី ដោយយានដ៏ថ្លៃថ្លា ។ បណ្តាស្តេចលិច្ឆវីទាំងនោះ ស្តេចលិច្ឆវីពួកខ្លះ ជាពួកខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងប្រដាប់ក៏ខៀវ ស្តេចលិច្ឆវីពួកខ្លះ ជាពួកលឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងប្រដាប់ក៏លឿង ស្តេចលិច្ឆវីពួកខ្លះ ជាពួកក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងប្រដាប់ក៏ក្រហម ស្តេចលិច្ឆវីពួកខ្លះ ជាពួក ស មានសម្បុរ ស មានសំពត់ ស មានគ្រឿងប្រដាប់ក៏ស ។ លំដាប់នោះ នាងអម្ពបាលីផ្កាមាស បំប៉ះកៀវដោយកៀវ បំប៉ះកង់ដោយកង់ បំប៉ះនឹមដោយនឹម(នៃយាន) របស់ពួកស្តេចលិច្ឆវីតំឡុះៗ។

អថខោ តេ(๑) លិច្ឆវី អម្ពបាលឹ គណិកំ ឯតទវោចុំ តឹ
ដ អម្ពបាលិ(๒) ឧមាកដំ ឧមាកដំ លិច្ឆវីនំ អក្ខេន
អក្ខំ ចក្កេន ចក្កំ យុត្តេន យុត្តំ បដិវដ្តេសីតិ ។
តថា ហិ បន មេ អយ្យបុត្តា ភគវា ឯមត្តំ តោ
ស្វាតនាយ ភត្តំ សង្ឃឹ ភិក្ខុសង្ឃេនាតិ ។ ឧទហិ
ដ អម្ពបាលិ ឯតំ ភត្តំ សតសហស្សេនាតិ ។
សចេ ហិ មេ អយ្យបុត្តា វេសាលឹ សាមន្តំ ឧស្សជ
ឯវំបិ(៣) មហន្តំ ភត្តំ ន ឧស្សក្ខមីតិ ។ អថខោ
តេ លិច្ឆវី អង្គុលឹ ចោឡេសុំ(៤) ឯតម្ហា វត ភោ
អម្ពបាលិកាយ(៥) វញ្ចិតម្ហា វត ភោ អម្ពបាលិកា-
យាតិ(៦) ។ អថខោ តេ លិច្ឆវី យេន អម្ពបាលិវនំ តេន
បាយឹសុ ។ អទ្ទសា ខោ ភគវា តេ លិច្ឆវី ទូរតោ
វ អាគច្ឆន្តេ ឯិស្សាន(៧) ភិក្ខូ អាមន្តេសិ យេសំ ភិក្ខវេ

---

๑ ឱ. តេវិ បទំ នត្ថិ ។ ๒ ឯតទវោចុំ ភោសជ្ជំ ទូតកបាលិយំ អម្ពកត្តិ បទំ ទិស្សតិ ។
๓ ឱ. ឯវំ ។ ๔ ចោឡេសុន្តិបិ ។ ๕-๖ ឱ. ម. អម្ពកាយាតិ ។ ๗ ឱ. ម. ទិស្វា ។

ឯស្តេចលិច្ឆវីទាំងនោះ មានបន្ទូលនឹងនាងអម្ពបាលីដ្បាមាស យ៉ាងនេះថា ម្នាលមេអម្ពបាលី ហេតុអ្វីក៏នាងបំប៉ះភ្លៅដោយភ្លៅបំប៉ះតង់ដោយតង់ បំប៉ះនឹមដោយនឹម (នៃយាន) របស់ពួកស្តេចលិច្ឆវីកំឡុះ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្រទាំងឡាយ ប្រាថ្នាដ៏ខ្ញុំម្ចាស់ឆ្លើយយ៉ាងនោះ ព្រោះខ្ញុំម្ចាស់ ប្រាថ្នានិមន្តព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃដើម្បីឆាន់ភត្តក្នុងថ្ងៃស្អែក ។ ពួកស្តេចលិច្ឆវីមានបន្ទូលថា ម្នាលមេអម្ពបាលី នាងបូរឲ្យភត្តនេះមកយើងដោយតម្លៃ ចំនួន១សែនកហាបណៈចុះ ។ នាងអម្ពបាលីឆ្លើយថា បពិត្រព្រះអយ្យបុត្រទាំងឡាយ ទុកជាព្រះអង្គប្រទានក្រុងវេសាលីព្រមទាំងជនបទដល់ខ្ញុំម្ចាស់ ក៏ខ្ញុំម្ចាស់មិនព្រមថ្វាយនូវភត្តដ៏ប្រសើរយ៉ាងនេះឡើយ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ផ្ចាត់ព្រាមព្រះហស្តហើយពោលថា ម្នាលគ្រាយើង ពួកយើងនាងអម្ពបាលីឈ្នះបានហើយ តើហ្ន៎ ម្នាលគ្រាយើង ពួកយើងត្រូវនាងអម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ក៏បរយានទៅកាន់អម្ពបាលិវ័ន ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញស្តេចលិច្ឆវីទាំងនោះមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ

កិត្តិំ នេវ តាវត្តឹសា អធិដ្ឋបុព្ពា ឱលោកេថ កិត្តិវេ លិច្ឆវិបរិសំ អវលោកេថ កិត្តិវេ លិច្ឆវិបរិសំ ឧបសំហារថ កិត្តិវេ លិច្ឆវិបរិសំ តាវត្តឹសសទិសន្តិ ។ អថខោ តេ លិច្ឆវី យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកា ។ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯតមត្ថំ អារោចេសុ ។ ឯតមត្ថំ អារោចេសុំ ខោ តេ លិច្ឆវី ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ តេ លិច្ឆវី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ ឯតទវោចុំ អធិវាសេតុ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសិតំ(๑) ខោ មេ លិច្ឆវី ស្វាតនាយ អត្ថាលិកលាលិកាយ ភត្តន្តិ ។ អថខោ តេ លិច្ឆវី អញ្ញតរំ បោរិសំ ជានបទំ អាមន្តេសុំ ជានាហិ ត្វំ ភោ អម្ពបាលិវនាយ

๑ ឧ.ម. អធិវុត្ថំ ។

ពួកភិក្ខុណា មិនដែលឃើញពួកទេវតា នៅក្នុងឋានតាវត្តិង្ស ម្នាលភិក្ខុ
ទាំងឡាយ ភិក្ខុទាំងនោះចូរមើលលិច្ឆវិបរិសទ្យ ចូរសង្កេតមើលលិច្ឆវិ-
បរិសទ្យ ពិនិត្យមើលលិច្ឆវិបរិសទ្យ ដែលប្រហែលគ្នានឹងទេវតា នៅក្នុង
ឋានតាវត្តិង្ស ។ គ្រានោះ ស្តេចលិច្ឆវីទាំងនោះ ក៏ទៅដោយយានតំណត់
ត្រឹមតែដែលបរយានទៅបាន ហើយចុះអំពីយានស្តេចទៅដោយព្រះបាទ
ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ
ព្រះមានព្រះភាគរួចគង់ក្នុងទីសមគួរ ។ លុះស្តេចលិច្ឆវីទាំងនោះគង់ក្នុងទី
សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់
យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ ស្តេចលិច្ឆវីទាំងនោះ
លុះព្រះមានព្រះភាគ ទ្រង់ពន្យល់ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យ
អាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រាបបង្គំទូលព្រះមាន
ព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ
ព្រមទាំងព្រះភិក្ខុសង្ឃ ទទួលភត្តរបស់យើងខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃ
ស្អែក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលលិច្ឆវីទាំងឡាយ តថាគត
បានទទួលភត្ត របស់នាងអម្ពបាលីផ្កាមាស ដើម្បីឆាន់ក្នុងថ្ងៃស្អែករួចទៅ
ហើយ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងនោះផ្គាត់ព្រួមព្រះហស្តហើយ
ពោលថា ម្នាលគ្នាយើង ពួកយើងឲ្យទាន់អម្ពបាលីឈ្នះបានហើយតើហ្ន៎

วฺหิตมฺปิ วต เภา อมฺพปาลิคณิกายาติ ฯ อถโข เต
ลิจฺฉวี ภควาโต ปาฏิหาริยปกฺขา อนุโยคิตฺวา
อุฏฺฐายาสนา ภควนฺตํ อภิวาเทตฺวา ปทกฺขิณํ กตฺวา
ปกฺกมึสุ ฯ อถโข อมฺพปาลี คณิกา สยเมว
รถิยา อภิรุยฺห เยน สเก อารามเก ปฏิปาทิ ยานปฺปเทสา
เยน ยานปฺปเทสา ปฏิยาทาเปตฺวา ภควาโต กาลํ อาโรจา-
เปสิ กาโล ภนฺเต นิฏฺฐิตํ ภตฺตนฺติ ฯ อถโข ภควา
ปุพฺพณฺหสมยํ นิวาเสตฺวา ปตฺตจีวรมาทาย สทฺธึ
ภิกฺขุสงฺฆเปน เยน อมฺพปาลิคณิกาย ปริวีมสนํ(๑)
เตนุปสงฺกมิ อุปสงฺกมิตฺวา ปญฺญตฺเต อาสเน นิสี
ทิ ฯ อถโข อมฺพปาลี คณิกา พุทฺธปฺปมุขํ
ภิกฺขุสงฺฆํ ปณีเตน ขาทนียเปน โภชนียเปน สย
หตฺถา สนฺตปฺปยิ สมฺปวาเรสิ ฯ อถโข อมฺพปาลี
คณิกา ภควนฺตํ ภุตฺตาวึ ทีนปตฺตปาณึ เอตทโวจ

๑ ฉ. ปริวีมสนา ฯ ม. ปริวีมสนํ ฯ

ម្ចាស់គ្រាយើង៎ ពួកយើង៎ឲ្យនាង៎អម្ពបាលីបញ្ឆោតបានហើយហ្ន៎ ។ លំដាប់នោះ ស្តេចលិច្ឆវីទាំង៎នោះ ត្រេកអរពេកពាយនឹង៎ភាសិត របស់ព្រះមានព្រះភាគហើយ ក៏ក្រោកចាកអាសន:ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។ លុះកន្លង៎ពួកត្រីនោះទៅហើយ នាង៎អម្ពបាលីផ្កាមាសតាក់តែង៎ខាទនីយភោជនីយាហារ ដ៏ថ្លៃថ្លាក្នុង៎អាវាមរបស់ខ្លួនហើយឲ្យបម្រើទៅក្រាបទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គ៎ដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់នឹង៎ចាត្រចីវរអំពីព្រលឹម ស្តេចសំដៅទៅកាន់ទីអង្គាសចង្ហាន់របស់នាង៎អម្ពបាលីផ្កាមាសព្រមដោយភិក្ខុសង្ឃ លុះស្តេចទៅដល់ហើយក៏គង់លើអាសន:ដែលគេក្រាលថ្វាយ ។ គ្រានោះ នាង៎អម្ពបាលីផ្កាមាសបានអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសារដោយដៃខ្លួនឯង៎ ឲ្យឆ្អែតស្កប់ស្កល់ គ្រាតែហាមឃាត់ ។ លំដាប់នោះ នាង៎អម្ពបាលីផ្កាមាសកំណត់ដឹង៎ថា ព្រះមានព្រះភាគ ទ្រង់សោយស្រេចហើយ លែង៎លូកព្រះហស្តទៅក្នុង៎ចាត្រហើយ ក៏កាន់យកអាសន:តូចមួយ អង្គុយក្នុង៎ទីដ៏សមគួរ ។ នាង៎អម្ពបាលីផ្កាមាសលុះអង្គុយ ក្នុង៎ទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគថា

ឥមាហំ ភន្តេ អាចរិយំ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ឧទ្ទិស្ស ។ បដិក្កមោសិ ភគវា អាចរិយំ ។ អថខោ ភគវា អម្ពដ្ឋាលឹ គណិកាំ ឆម្ភិយា ភិក្ខាយ សន្ធេស្សត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ តត្រ(๑) សុទំ ភគវា វេសាលិយំ វិហរន្តោ អម្ពដ្ឋាលិវនេ ឯតទេវ ពហុលំ ភិក្ខូនំ ឆម្ភិ ភគវំ ភគវោតិ ឥតិ សីលំ ឥតិ សមាធិ ឥតិ បញ្ញា សីលបរិភាវិតោ សមាធិ មហប្ផលោ ហោតិ មហានិសំសោ សមាធិបរិភាវិតា បញ្ញា មហប្ផលា ហោតិ មហានិសំសា បញ្ញាបរិភាវិតំ ចិត្តំ សម្មទេវ អាសវេហិ វិមុច្ចតិ សេយ្យថីទំ កាមាសវា ភវាសវា អវិជ្ជាសវាតិ ។

(๙๓) អថខោ ភគវា អម្ពដ្ឋាលិវនេ យថាភិរន្តិំ វិហរិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន វេឡុវគាមកោ(๒) តេនុបសង្កមិស្សាមាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្চស្សោសិ ។ អថខោ ភគវា មហតា ភិក្ខុសង្ឃេន សទ្ធិំ យេន វេឡុវគាមកោ តទវសរិ ។ តត្រ សុទំ ភគវា

๑ ឧ. តត្របិ ។ ๒ ឧ. ពេឡុវគ្គាមកោ ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមថ្វាយអាភមនេះ ដល់ព្រះកិកុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលនូវអាភម ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ញុំាងនាងអម្ពបាលីឯ្លាមាស ឲ្យឃើញ ច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈស្តេចចេញទៅ ។ បានឮថា ព្រះមានព្រះភាគដែលទ្រង់គង់ក្នុងអម្ពបាលិវ័ន ទៀបក្រុងវេសាលីនោះ ទ្រង់ធ្វើធម្មីកថាជាច្រើន ដល់កិកុទាំងឡាយយ៉ាងនេះថា សីលដូច្នេះ សមាធិដូច្នេះ បញ្ញាដូច្នេះ សមាធិដែលអប់រំដោយសីលហើយ រមែងមានផលច្រើន មានអានិសង្សច្រើន បញ្ញាដែលអប់រំដោយសមាធិហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ចិត្តដែលអប់រំដោយបញ្ញាហើយ រមែងរួចស្រឡះចាកអាសវៈទាំងឡាយដោយប្រពៃ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។

(๙๓) លុះព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពបាលិវ័ន តាមសមគួរ ដល់ពុទ្ធអធ្យាស្រ័យហើយ បានត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅ កាន់វេឡុវគ្រាម ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅដល់វេឡុវគ្រាម ព្រមដោយកិកុសង្ឃជាច្រើន ។ បានឮថា

เวฬุวคามเกเยว วิหรถ ฯ ตตฺร โข ภควา ภิกฺขู อา-
มนฺเตสิ อิติ ภูตมิทํ ภิกฺขเว สมฺปทา เวสาลี ยถาปิทํ
ยถาสนฺถฏฺฐิ ยถาสมฺภตฺตํ วสฺสูปคตา[๑] อถโข
ปน ตฺวเญว เวฬุวคามเกเยว วสฺสูปคจฺฉาหิ ฯ ฯเปฯ
ภนฺเตติ โข เต ภิกฺขู ภควโต ปฏิสฺสุณิตฺวา[๒] สา-
มนฺตา เวสาลึ ยถาปิทํ ยถาสนฺถฏฺฐิ ยถาสมฺภตฺตํ
วสฺสูปคจฺฉึ[๓] ฯ ภควา ปน ตตฺเรว เวฬุวคามเกเย
วสฺสูปคจฺฉิ ฯ อถโข ภควโต วสฺสูปคตสฺส ๑เยว
อาพาโธ อุปปชฺชิ พาฬฺหา เวทนา วตฺตนฺติ มรณนฺติกา ฯ
ตตฺร สุทํ ภควา สโต สมฺปชาโน อธิวาเส-
สิ[๔] อวิหญฺญมาโน ฯ อถโข ภควโต ฯเปฯ เหาเ-
สิ น โข เมตํ ปฏิรูปํ โยหมฺหิ[๕] อนามนฺเตฺวา อุ-
ปฏฺฐาเกเย อนุปลาเกตฺวา ภิกฺขุสงฺฆํ ปริโนิพฺพายิสฺสา

---

๑ ฉ. ม. ๑เปฯ ๒ ฉ. ม. ปฏิสฺสุตฺวา ฯ ๓ ฉ. ๑ปคจฺฉุ ฯ ม. ๑ปคจฺฉึสุ ฯ
๔ ฉ. อธิวาเสตฺวา ฯ ๕ ม. สฺวหํ ฯ

ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងវេឡុវគ្រាមនោះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមក ចូរអ្នកទាំងឡាយ ទៅចាំវស្សាក្នុងទីជិត ។ ក្រុងវេសាលី តាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលស្គាល់គ្នា តាមបុគ្គលដែលស្និទ្ធស្នាលនឹងគ្នាចុះ ចំណែកតថាគតនឹងនៅចាំវស្សាក្នុងវេឡុវគ្រាមនេះឯង ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏នាំគ្នាទៅចាំវស្សាក្នុងទីជិត ។ ក្រុងវេសាលី តាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលស្គាល់គ្នា តាមបុគ្គលដែលស្និទ្ធស្នាលនឹងគ្នា ។ ចំណែកខាងព្រះមានព្រះភាគ ទ្រង់ចាំវស្សាក្នុងវេឡុវគ្រាមនោះឯង ។ កាលព្រះមានព្រះភាគ ទ្រង់គង់ចាំព្រះវស្សា ក៏មានព្រះអាពាធខ្លាំងក្លាកើតឡើង វេទនាដ៏មានកម្លាំងស្ទើរនឹងដល់មរណៈក៏ប្រព្រឹត្តទៅ ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់មានសតិនឹងសម្បជញ្ញៈ មិនឲ្យទុក្ខវេទនាបៀតបៀនបាន ទ្រង់អត់សង្កត់ (ដោយអធិវាសនខន្តី) ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតមិនបានប្រាប់ពួកភិក្ខុអុបដ្ឋាក ទើមិនបានប្រាប់ភិក្ខុសង្ឃហើយបរិនិព្វាន ដោយហេតុណា ហេតុនោះមិនសមគួរ

ยนฺนูนาหำ ฯเปฯ อาคาฬำ วิหารำ ปฏิปฺปณาเมตฺวา ปี-
ติสงฺขารำ อภิฏฺฐาย วิหาเรยฺยนฺติ ฯ อถโข ภควา ตำ
อาคาฬำ วิหารำ ปฏิปฺปณาเมตฺวา ปีติสงฺขารำ อภิฏฺฐาย
วิหาสิ ฯ อถโข ภควาโต เสา อาคาฬา ปฏิ-
ปฺปสฺสทฺธิ ฯ อถโข ภควา ตสฺมิงฺ ฐาเน ปฺญฺญตฺเต อภิปฺปสฺ-
เต เคลญฺญา วิหาก ภิกฺขุ วิหารปจฺจายายำ
ปญฺญตฺเต อาสเน นิสีทิ ฯ อถโข อายสฺมา อา-
นนฺโท เยน ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา
ภควนฺตำ อภิวาเทตฺวา เอกมนฺตำ นิสีทิ ฯ เอกมนฺตำ
นิสินฺโน โข อายสฺมา อานนฺโท ภควนฺตำ เอตทโวจ
ทิฏฺฐา[๑] ภนฺเต ภควาโต ชานฺนุ ทิฏฺฐา[๒] ภนฺเต ภควาโต
ขมนียำ อปจิ[๓] เม ภนฺเต มญฺญาตกชาโต วิย กา-
โย นิสาปิ เม น ปกฺกายนฺติ ธมฺมาปิ มำ น ปฏิภนฺติ

---

๑ ฉ. ทิฏฺฐา เม ฯ ม. ทิฏฺฐา เม ฯ ๒ ฉ. ทิฏฺฐำ เม ฯ ๓ ฉ. อปิ หิ ฯ

ដល់តថាគតឡើយ បើដូច្នោះគួរតែតថាគតគ្រប់សង្កត់អាពាធនេះ ដោយសេចក្តីព្យាយាម ហើយអធិដ្ឋានជីវិតសង្ខារសម្រេចតរិយោបថសិនចុះ ។ ទើបព្រះមានព្រះភាគ ទ្រង់គ្រប់សង្កត់អាពាធនោះ ដោយសេចក្តីព្យាយាម ហើយទ្រង់អធិដ្ឋានទ្វជីវិតសង្ខារ ។ អាពាធនៃព្រះមានព្រះភាគនោះក៏រម្ងាប់ទៅក្នុងកាលនោះឯង ។ លុះព្រះអានព្រះភាគ សះស្បើយអំពីព្រះអាពាធហើយ ទើបនឹងស្បើយចាកពីអាពាធមិនយូរប៉ុន្មាន ទ្រង់ស្តេចចេញអំពីវិហារទៅគង់លើអាសនៈ ដែលគេបានក្រាលទុកត្រង់មុខវិហារ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញព្រះមានព្រះភាគ ទ្រង់បានសេចក្តីសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឃើញព្រះមានព្រះភាគអត់ធន់បាន បពិត្រព្រះអង្គដ៏ចម្រើន ក៏កាយរបស់ខ្ញុំព្រះអង្គហាក់ដូចជាស្រយុតស្រយង់ពេកណាស់ សូម្បីទិសទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ សូម្បីធម៌ទាំងឡាយក៏មិនច្បាស់លាស់ ដល់ខ្ញុំព្រះអង្គ

